រឿងក្តីទាមទារឲ្យប្រគល់ប្រាក់កម្ចី រឿងក្តីរដ្ឋប្បវេណីលេខ ៨១៩ ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១៤ [1]

ដើមចោទ X

ចុងចម្លើយ Y

# លិខិតពន្យល់អំពីភស្តុតាង [9]

ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១៤

សូមគោរពជូន លោកចៅក្រម J នៃសាលាដំបូងរាជធានីភ្នំពេញ

មេធាវីតំណាងដោយអាណត្តិរបស់ដើមចោទ P

| ភស្តុតាង [2] | **មាតិកា** [3] (ច្បាប់ដើម・ច្បាប់ចម្លង [4]) | | កាលបរិច្ឆេទនៃការបង្កើត ថ្ងៃ..ខែ..ឆ្នាំ.. [5] | អ្នកបង្កើត [6] | គោលបំណងនៃការបញ្ជាក់ [7] | ផ្សេងៗ |
|---|---|---|---|---|---|---|
| X1 | លិខិតកិច្ចសន្យាខ្ចីប្រាក់ | ច្បាប់ដើម | ០១ វិច្ឆិកា ២០០៧ | X, Y | អង្គហេតុដែលដើមចោទ និងចុងចម្លើយបានចុះកិច្ចសន្យាខ្ចីប្រាក់ នៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០០៧ និង ខ្លឹមសារនៃកិច្ចសន្យានោះ | |
| X2 | បង្កាន់ដៃទទួលប្រាក់ | ច្បាប់ដើម | ០១ វិច្ឆិកា ២០០៧ | Y | អង្គហេតុដែលដើមចោទប្រគល់ប្រាក់ ១០០០០ដុល្លារ ទៅឲ្យចុងចំលើយ នៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០០៧ | |
| X3 [8] | បង្កាន់ដៃ | ច្បាប់ដើម | ៣១ តុលា ២០១២ | X | អង្គហេតុដែលដើមចោទបានទទួលប្រាក់សងមួយផ្នែកពីចុងចម្លើយចំនួន ១០០០ដុល្លារ នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១២ | |

(សេចក្តីពន្យល់)

1. សរសេរនូវពត៌មានដែលកំណត់អំពីសំណុំរឿង ដូចជា លេខសំណុំរឿង ឈ្មោះដើមចោទ និង ឈ្មោះចុងចម្លើយជាអាទិ៍។

2. ដាក់ដោយភ្ជាប់ជាមួយលេខសម្គាល់ ដូចជា ភស្តុតាងដាក់ដោយដើមចោទដាក់ថា "X1" "X2" "X3" … ភស្តុតាងដាក់ដោយចុងចម្លើយដាក់ថា "Y1" "Y2" "Y3" … ។

3. សរសេរចំណងជើងនៅលើឯកសារជាអាទិ៍។

4. សរសេរអំពីភស្តុតាងដែលត្រូវដាក់ថា ជាច្បាប់ដើម ឬ ជាច្បាប់ចម្លង ដើម្បីងាយស្រួលយល់។

5. សរសេរអំពីថ្ងៃខែឆ្នាំដែលបានបង្កើតភស្តុតាងដែលត្រូវដាក់។

6. សរសេរអំពីអ្នកធ្វើភស្តុតាងដែលដាក់ទៅ។

7. ត្រូវតែសរសេរ និង កំណត់ឲ្យបានដាក់លាក់អំពីអង្គហេតុដែលត្រូវបញ្ជាក់ ចំពោះភស្តុតាងដែលត្រូវដាក់ (ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា 125 កថាខណ្ឌទី1 )។

8. ករណីដែលដាក់ភស្តុតាងបន្ថែម ត្រូវបង្កើតខ្ទង់ថ្មី "X4" នៅខាងក្រោមខ្ទង់ "X3" ហើយសរសេរបន្ថែម ។ ដាក់ឯកសារដែលបានសរសេរបន្ថែម ពោល គឺឯកសារដែលបានសរសេរអំពីភស្តុតាងដែលបានដាក់ទាំងអស់ ទៅកាន់តុលាការ ។

9. នៅពេលធ្វើការស្នើសុំឲ្យពិនិត្យភស្តុតាងជាឯកសារ (ក្រមនីតិវិធីរដ្ឋប្បវេណី ចាប់ពីមាត្រា 148) គួរតែដាក់នូវលិខិតពន្យល់អំពីភស្តុតាង និង ច្បាប់ចម្លងនៃឯកសារនេះទៅកាន់តុលាការ។ យ៉ាងណាមិញ ក្នុងករណីដែលដាក់វត្ថុដែលទុកដូចជាឯកសារ (ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា158) ត្រូវប្រើប្រាស់លិខិតពន្យល់អំពីភស្តុតាងនេះ។ ឧទាហរណ៍ជាក់ស្តែងក្នុងករណីដែលដាក់រូបថតធ្វើជាវត្ថុដែលទុកដូចជាឯកសារ មានដូចនៅក្នុងទំព័របន្ទាប់។

ឧទាហរណ៍) ករណីដែលដាក់រូបថត (5សន្លឹក) ជាភស្តុតាង Y4(1)~(5)

| ភស្តុតាង | មាតិកា<br>(ច្បាប់ដើម・ច្បាប់ចម្លង) | កាលបរិច្ឆេទនៃការបង្កើត<br>ថ្ងៃ..ខែ..ឆ្នាំ.. | អ្នកបង្កើត | គោលបំណងនៃការបញ្ជាក់ | ផ្សេងៗ |
| --- | --- | --- | --- | --- | --- |
| Y1 ~ Y3 | សង្ខេប | | | | |
| Y4<br>(1)~(5) | រូបថត<br>រូបភាពទាំងស្រុង រថយន្ត<br>ពេលវេលាថតរូប ថ្ងៃទី31 ខែតុលា ឆ្នាំ2013<br>អ្នកថតរូប ចុងចម្លើយ | | | នៅថ្ងៃទី31 ខែតុលា ឆ្នាំ2013 ដើមចោទបានទិញរថយន្តពីចុងចម្លើយ។ | |